# ក្រឹត្យ-ច្បាប់

ស្តីពី

# ក្រឹត្យ-ច្បាប់

# ការចាត់តាំងតុលាការយោធា

## ក្រុមប្រឹក្សារដ្ឋ

បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណៈរដ្ឋប្រមានិតកម្ពុជា។

ដើម្បីការពារសន្តិសុខ ការពារប្រទេស ការពារកម្លាំងប្រយុទ្ធ របស់កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តកម្ពុជា ពង្រឹងវិន័យរបស់កងទ័ព និង ការពារនិត្យានុកូលភាព។

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារ ប្រទេស និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ព្រមផង។

## សំរេច

**មាត្រា ១**- ត្រូវបានបង្កើតតុលាការយោធា ដើម្បីជំនុំជំរះ។

យោធាដែលប្រព្រឹត្តបទល្មើស ដូចមានកំណត់ក្នុងក្រឹត្យ - ច្បាប់ លេខ ០២ ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ១៩៨០ ឬបទល្មើសដែលមានលក្ខណៈ យោធា ឬ បទល្មើសផ្សេងៗ ទៀត ដែលមានចែងក្នុងច្បាប់ជាធរមាន។

ជនទាំងឡាយដែលធ្វើការក្រោមការគ្រប់គ្រងរបស់ក្រសួងការពារប្រទេស ហើយប្រព្រឹត្តបទល្មើសដែលមានការទាក់ទងដល់កងទ័ព។

ជនណា ដែលប្រព្រឹត្តបទល្មើសបបណ្តាលអោយប៉ះពាល់ដល់ផលប្រយោជន៍របស់កងទ័ព។

បើនៅក្នុងរឿងណាមួយ មានយោធា និង ជនស៊ីវិល ប្រព្រឹត្តបទ ល្មើសជាមួយគ្នាតាមគោលការណ៍បទល្មើសនេះ ត្រូវចូលក្នុងសមត្ថកិច្ចរបស់ តុលាការយោធា។ ប៉ុន្តែ យោងទៅតាមលក្ខណៈនៃបទល្មើសនីមួយៗ តុលាការយោធា អាចសំរេចបំបែករឿងផ្សេងពីគ្នា ហើយជំនុំជំរះតែយោធា ចំណែក ជនស៊ីវិល ត្រូវបញ្ជូនទៅតុលាការប្រជាជនជំនុំជំរះ។ ក្នុងករណីពិសេសតុលាការរយោធា អាចបញ្ជូនសំណុំរឿងទាំងមូល ទៅតុលាការប្រជាជនជំនុំជំរះ ។

**មាត្រា ២**- តុលាការយោមាន ប្រធាន អនុប្រធាន និងចៅក្រមម្នាក់ទៀតជាសមាជិក។

នៅពេលជំនុំជំរះ ក្រុមប្រឹក្សាជំនុំជំរះ មានចៅក្រមម្នាក់ជាប្រធាន និង យោធាពីរនាក់ ជាទីប្រឹក្សា។

ទីប្រឹក្សាយោធ មានសិទ្ធិស្មើនឹងចៅក្រម។

ក្រុមប្រឹក្សាជំនុំជំរះ ធ្វើការជាសមូហភាព និងសំរេចតាមមតិភាគច្រើន។

លេខាធិការនៃសវនាការ ត្រូវកត់ត្រា និងធ្វើកំណត់ហេតុនៃការជំនុំជំរះ ព្រមទាំងបំពេញភារកិច្ចផ្សេងទៀត តាមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រ ៣**- តំណាងអយ្យការមាន រដ្ឋអាជ្ញាយោធា និង រដ្ឋអាជ្ញាការយោធា។ រដ្ឋអាជ្ញាយោធា មានភារកិច្ចសំរេច ពីការលើកលែងចោទប្រកាន់ ឬ ពីការចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ការពារការចោទប្រកាន់នៅមុខតុលាការយោធា ហើយរ៉ាប់រងការអនុវត្តន៍សាលក្រម អោយបានសមស្របតាមច្បាប់។

**មាត្រា ៤**- បើមានបទល្មើសមួយកើតឡើង អាជ្ញាធរយោធាចាប់ពីថ្នាក់កងអនុសេនាធំ និងកងវរសេនាតូចឡើងទៅ ព្រមទាំងកម្មាភិបាលយោធាទទួលបន្ទុកស៊ើបអង្កេតរឿង ត្រូវចាត់ជាបន្ទាន់នូវវិធានការចាំបាច់ និង ស្របច្បាប់ ដើម្បីចាប់ជនប្រព្រឹត្តបទល្មើស រក្សាទុកដាន និងសញ្ញា ជួយព្យាបាលជាបន្ទាន់ដល់ជនរងគ្រោះមានរបួស ការពារទ្រព្យសម្បត្តិសាធារណៈ ការពារអាយុជីវិត និង ទ្រព្យសម្បត្តិរបស់ប្រជាជន ប្រមូលឯកសារ និងភស្តុតាង ដែលទាក់ទងនឹងបទល្មើស ធ្វើការអង្កេតស៊ើបសួរ ហើយបញ្ជូនសំណុំរឿងមក រដ្ឋអាជ្ញាយោធា។

**មាត្រា ៥**- សេចក្តីសំរេចចោទប្រកាន់ និង សេចក្តីសំរេចដាក់រឿងជំនុំជំរះ ត្រូវអោយដំណឹងដល់ជនជាប់ចោទ ពីថ្ងៃយ៉ាងយូរមុនថ្ងៃជំនុំជំរះ។

**មាត្រា ៦** - សិទ្ធិការពារខ្លួនរបស់ជនឆាប់ជាងត្រូវបានធានា។

ជនជាប់ចោទមានសិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ ពឹងអ្នកដទៃណាមួយអោយជួយការពារ។ ក្នុងករណីចាំបាច់តុលាការយោធាអាចចាត់តាំងមេធាវីម្នាក់អោយ ជួយការពារដល់ជនជាប់ចោទ។

**មាត្រា៧**- តុលាការយោធា ជំនុំជំរះជាលើកទី១ និងជាលើកចុងក្រោយបង្អស់។ សាលក្រម និងសេចក្តីសំរេចទាំងឡាយ របស់តុលាការយោធា មានលក្ខណៈជាស្ថាពរ គួរក្តី គ្មានសិទ្ធិប្តឹងឧទ្ធរណ៍ឡើយ។ ប៉ុន្តែ សាលក្រមកាត់កាសប្រហារជីវិត ត្រូវដាក់ជូនក្រុមប្រឹក្សារដ្ឋពិនិត្យជាមុខសិន មុននឹងយកទៅអនុវត្ត។ ជនដែលត្រូវបានផ្តន្ទាទោសប្រហារជីវិត អាចសុំអនុគ្រោះទោស ពីក្រុមប្រឹក្សារដ្ឋក្នុងរយៈ៧ថ្ងៃ គិតតាំងពីថ្ងៃដែលប្រកាសសាលក្រម។

**មាត្រា ៨**- ប្រធានតុលាការយោធា អនុប្រធានតុលាការយោធា ចៅក្រម និងតំណាងអយ្យការយោធា ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងការពារប្រទេស។ ទីប្រឹក្សាយោធា ត្រូវបានជ្រើសរើសដោយអង្គការទទួលបន្ទុក កិច្ចការនយោបាយនៃកងទ័ព។

**មាត្រា៩**- រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលអនុវត្តក្រឹត្យ-ច្បាប់នេះ តាមភារកិច្ចរៀងៗ ខ្លួន។

ភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៨១

ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

**ហេង សំរិន**

បានទទួលអនុវត្ត

ជា ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ចាន់ ស៊ី**